ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

N° ០០៧ ឧស៥. ធរ. សរណន.

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៤.

# សារាចរ

## ណែនាំស្តីពីវិធានការទប់ស្កាត់ការធ្វើអាជីវកម្មរ៉ែ អនាធិបតេយ្យនៅតាមបណ្តា ខេត្ត-ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា

នៅក្នុងរយៈពេលកន្លងមកនេះក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល បានពិនិត្យឃើញថា នៅតាមតំបន់នៃបណ្តាខេត្ត-ក្រុងមួយចំនួនតែងមានបាតុភាពធ្វើអាជីវកម្មរ៉ែអនាធិបតេយ្យ ដែលបានបំផ្លិចបំផ្លាញសម្បត្តិធនធានធម្មជាតិយ៉ាងធ្ងន់ធ្ងរដែលច្បាប់បានចែងថាជាសម្បត្តិរបស់រដ្ឋ ហើយដែលជាកត្តាធ្វើអោយបាត់បង់ចំណូលថវិការដ្ឋយ៉ាងច្រើនសម្បើម និងប៉ះពាល់ដល់បរិស្ថានធម្មជាតិក្នុងតំបន់ ។ ដូចជាការប្រើប្រាស់រំសេវជាតិផ្ទុះ និង សារជាតិគីមីដោយគ្មានលិខិតអនុញ្ញាត ដែលបានបង្កអោយមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុវត្ថិភាព សុខភាពមនុស្ស និងសត្វ ដែលរស់នៅក្នុង និង ជុំវិញតំបន់អាជីវកម្មរ៉ែអនាធិបតេយ្យទាំងនោះ ។

ដូច្នេះ ដើម្បីទប់ស្កាត់នូវរាល់សកម្មភាពធ្វើអាជីវកម្មរ៉ែអនាធិបតេយ្យ នៅតាមតំបន់នៃបណ្តាខេត្ត-ក្រុង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សូមធ្វើការណែនាំដល់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលគ្រប់ខេត្ត-ក្រុង អនុវត្តដូចខាងក្រោម ៖

**I-ចំពោះការធ្វើអាជីវកម្មរ៉ែអនាធិបតេយ្យ ៖**

១-ត្រួតពិនិត្យ និងស្រង់ទីតាំងការដ្ឋានអាជីវកម្មរ៉ែអនាធិបតេយ្យ ដែលមាននៅក្នុងខេត្ត-ក្រុងរបស់ខ្លួនដោយសហការជាមួយអាជ្ញាធរដែនដី ដើម្បីចាត់វិធានការទប់ស្កាត់យ៉ាងតឹងរ៉ឹងចំពោះការធ្វើអាជីវកម្មរ៉ែអនាធិបតេយ្យ អោយមានប្រសិទ្ធិភាព ។

២-សហការជាមួយអាជ្ញាធរដែនដី ដើម្បីត្រួតពិនិត្យសកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យដូចខាងក្រោម ៖

- ទប់ស្កាត់ការដឹកជញ្ជូនចល័តនូវរំសេវជាតិផ្ទុះ និង សារជាតិគីមី ដែលរដ្ឋបានហាមឃាត់ ដើម្បីយកមកប្រើប្រាស់ក្នុងអាជីវកម្មរ៉ែអនាធិបតេយ្យ ។
- គ្រប់គ្រង និង ទប់ស្កាត់ប្រជាពលរដ្ឋចំណូលថ្មី ដែលមានបំណងចូលមកតំបន់របស់ខ្លួនដើម្បីចូលរួមធ្វើអាជីវកម្មរ៉ែអនាធិបតេយ្យ ។
- គ្រប់គ្រងសិប្បកម្មកែឆ្នៃគ្រឿងចក្រចល័តធុនធ្ងន់ សំរាប់បំរើអោយការធ្វើអាជីវកម្មធនធានរ៉ែអនាធិបតេយ្យ ។
- ត្រួតពិនិត្យសិប្បកម្មកែឆ្នៃសំភារៈឧបករណ៍ធុនស្រាល (ដែកស្បែង កញ្ច្រែង ដួន) បំរើអោយការធ្វើអាជីវកម្មរ៉ែអនាធិបតេយ្យ ។
- ទប់ស្កាត់ការស្វែងរុករក ឬការធ្វើអាជីវកម្មធនធានរ៉ែ ដោយប្រើប្រាស់រូបភាពខ្នងបង្អែកអ្នកមានអំណាចណាមួយក្នុងមូលដ្ឋាន ដោយគ្មានអាជ្ញាប័ណ្ណពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- ត្រូវរាយការណ៍ជូនក្រសួងជាប្រចាំអំពីលទ្ធផលនៃការចុះត្រួតពិនិត្យ និងបិទការធ្វើអាជីវកម្មរ៉ែអនាធិបតេយ្យ និងវាយតំលៃផលប៉ះពាល់បរិស្ថាន និង លើកវិធានការចាំបាច់ដាក់ជូនក្រសួងពិនិត្យ និងសំរេច ។

II-**ចំពោះក្រុមហ៊ុនឬអាជីវករ ដែលមានអាជ្ញាប័ណ្ណធនធានរ៉ែពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** :

-ត្រូវត្រួតពិនិត្យសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដើម្បីស្វែងរុករក និង ធ្វើអាជីវកម្មធនធានរ៉ែ នៅតំបន់របស់ខ្លួន និង តាមដានត្រួតពិនិត្យរាល់សកម្មភាពប្រតិបត្តិការធនធានរ៉ែអោយស្របតាមលក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណធនធានរ៉ែ ដែលក្រសួងបានចេញអោយសម្បទានិកនោះ ក្រោមកិច្ចព្រមព្រៀងដែលនៅជាធរមាន ។

ទទួលបានសារាចរណែនាំនេះ សូមលោកប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង អនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ ។/.

ស៊ុយ_សែម

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្ត-ក្រុង ដើម្បីជូនជ្រាប
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ